**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ**

**អគ្គនាយកដ្ឋានរដ្ឋបាល**

លេខ : ១៣៧០៧/អរ.ភប

ថ្ងៃ ៣ ៦ កើត ខែ ចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០១៨

## ជម្រាបជូន

**ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ** : ស្ដីពីការផ្សព្វផ្សាយជ្រើសរើសនិស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ ទៅសិក្សានៅសាកលវិទ្យាល័យស៊ុនយ៉ាតសេន (Sun Yat-sen University) ទីក្រុងក្វាងចូវ នៃសាធារណរដ្ឋប្រជាមានិតចិន សម្រាប់ឆ្នាំ២០១៨។

**យោង** : លិខិតលេខ ១៧ អយក.ស.ជ.ណ ចុះថ្ងៃពុធ ១២កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងអប់រំ យុវជន និងកីឡា។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ** ថា សាកលវិទ្យាល័យស៊ុនយ៉ាតសេន (Sun Yat-sen University) នៅទីក្រុងក្វាងចូវ នៃសាធារណរដ្ឋប្រជាមានិតចិន នឹងផ្ដល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រចំនួន៣០កន្លែង ដល់និស្សិតកម្ពុជាក្រោមកម្មវិធី "Undergraduate Scholarship Programme for International students" លើមុខវិជ្ជាសិក្សាដូចជា Economics, Management, Science and Engineering, Medical and Arts សម្រាប់ឆ្នាំ២០១៨នេះ។

ចំពោះបេក្ខជន បេក្ខនារីដែលមានចំណាប់អារម្មណ៍លើកម្មវិធីអាហារូបករណ៍ខាងលើសូមស្វែងរកពាក្យសុំដើម្បីបំពេញសំណុំបែបបទតាមរយៈគេហទំព័រ: http://application.sysu.edu.cn។ សម្រាប់ព័ត៌មានបន្ថែមសូមសាកសួរតាមរយៈអ៊ីម៉ែល: admissions@mail.sysu.edu.cn និងគេហទំព័រ: http://iso.sysu.edu.cn/ ឬទូរស័ព្ទលេខ: ០០៨៦-២០-៨៤១១០៨១៩/៨៤១១០៨៤៨ រួចបញ្ជូនពាក្យសុំទៅកាន់ក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ អគារលេខ៨០ មហាវិថីព្រះនរោត្តមស្ថិតក្នុងទីស្ដីការក្រសួង) ឱ្យបានមុនថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាប និងចាត់ចែងផ្សព្វផ្សាយដល់មន្ត្រីរាជការក្រោមឱវាទឱ្យបានទូលំទូលាយតាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**អគ្គនាយក**

ប្រាក់ សំអឿន

**សូមទំនាក់ទំនង:**

- លោក ងួន គីមសេង
- ទូរស័ព្ទលេខ: ០១១ ៣២២ ២២៧